ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

*******

តុលាការកំពូល

សភាផ្នែករដ្ឋប្បវេណី

សំណុំរឿងរដ្ឋប្បវេណី
លេខ ២៣៣
ចុះថ្ងៃទី២៥ខែសីហាឆ្នាំ១៩៩៨

សាលដីកា
លេខ : ២៣៤
ចុះថ្ងៃទី១៥ខែធ្នូឆ្នាំ១៩៩៨

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ១៩៩៨ ដោយមានសមាសភាពដូចតទៅ :

| | | | | |
|---|---|---|---|---|
| ១- | ឯកឧត្តម | ឌិត | មុន្ទី | ប្រធាន |
| ២- | លោក | ប៉ែន | ស៊ុន | ចៅក្រមរបាយការណ៍ |
| ៣- | លោក | ប៉ុល | មួន | ចៅក្រម |
| ៤- | លោក | ស៊ិន | ខឹម | ចៅក្រម |
| ៥- | លោក | ជីវ | កេង | ចៅក្រម |

ក្រឡាបញ្ជី

លោក ទៀវ ដាណា

តំណាងមហាអយ្យការ

លោក ជួន ស៊ុនឡេង ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ៣១៧ ចុះថ្ងៃទី២២-៦-៩៨ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ២១៥ ចុះថ្ងៃទី ០៧-៥-៩៦ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ ពៅ ប៊ុង ភេទស្រី អាយុ ៦៨ ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ មានទីលំនៅភូមិក្រញូង ឃុំពោធិអង្រ្គង ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ។

និងចុងចម្លើយបណ្តឹងសាទុក្ខឈ្មោះ ហោ លន ភេទស្រី អាយុ ៥៥ឆ្នាំ ជាតិខ្មែរ មុខរបរលក់ដូរ ធ្វើស្រែ មានទីលំនៅ ភូមិក្រញូង ឃុំពោធិអង្រ្គង ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ។ ឪពុកឈ្មោះ ហោ កៅ "ស" ម្តាយឈ្មោះ អោ ដារ "ស" ប្តីឈ្មោះ ពេជ្រ ជីម ។

<u>កម្មវត្ថុបណ្តឹង</u> : ប្តឹងទាមទារដី

បានឃើញបណ្តឹងសាទុក្ខលេខ ២៧២ ចុះថ្ងៃទី ០៩-៧-១៩៩៨ របស់មេធាវីឈ្មោះ ចាំង សុធា គារពារប្រជាជន១៨គ្រួសារ ប្តឹងមិនសុខចិត្តនឹងសេចក្តីសំរេចរបស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ២៣៣ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ១៩៩៨ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ០៥-៦-៩៥ របស់ដើមចោទឈ្មោះ ហេង លន ប្តឹងសុំឱ្យចុងចម្លើយរុះរើផ្ទះចេញពីដីកម្មសិទ្ធិរបស់ខ្លួនដោយសំអាងហេតុថា កាលពីមុនឈ្មោះនេះ បានសង់ផ្ទះលើដីចិញ្ចើមផ្លូវជាតិលេខ ៣ ដល់ពេលរដ្ឋអំណាចរៀបចំផ្លូវបត់នៅឆ្នាំ១៩៩១ ឱ្យប្រជាជន ១៨ គ្រួសាររុះរើថយក្រោយចម្ងាយ ៣៥ម. ពីផ្លូវជាតិ ស្រាប់តែថយទៅជាន់លើដីកម្មសិទ្ធិរបស់ខ្លួនដែលបានធ្វើពាក្យសុំកាន់កាប់តាំងពីឆ្នាំ ១៩៨៩ ហើយមានបណ្ណកម្មសិទ្ធិនៅឆ្នាំ ១៩៩២ ។

បានឃើញ សាលក្រមរដ្ឋប្បវេណីលេខ ០៤ ចុះថ្ងៃទី១០-១១ ខែមករា ឆ្នាំ១៩៩៦ របស់តុលាការខេត្តកំពង់ស្ពឺ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ ៖

១- ទទួលពាក្យបណ្តឹងរបស់ដើមចោទ ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ១៩៩៥ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- ទទួលស្គាល់បណ្ណសំគាល់កម្មសិទ្ធិ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩២ របស់ដើមចោទ ទុកជាត្រឹមត្រូវ ចាប់ពីថ្ងៃនេះតទៅ ។

៣- បដិសេធបណ្តឹងតប ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ ១៩៩៥ និង លិខិតផ្សេងៗ របស់ចុងចំលើយចោលជាអសារបង់ដោយខុសគតិច្បាប់ ។

៤- ប្រគល់ដីកើតហេតុនេះ ឱ្យទៅដើមចោទ គ្រប់គ្រងជាកម្មសិទ្ធិចាប់តាំងពីថ្ងៃនេះតទៅ តាមមាត្រា ៣ នៃច្បាប់ភូមិបាល ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ១០០ក្រ ចុះថ្ងៃទី ១៣ ខែតុលា ឆ្នាំ១៩៩២ ។

៥- ឱ្យចុងចម្លើយរុះរើផ្ទះចេញពីដីកើតហេតុនេះ ចាប់តាំងពីថ្ងៃនេះតទៅ បើមិនព្រមរុះរើចេញទេ ត្រូវបង់ប្រាក់ថ្លៃដីឱ្យទៅដើមចោទតាមតម្លៃដីនៅមូលដ្ឋាននោះ ។

៦- សាលក្រមនេះ ប្រកាសជាសាធារណៈចំពោះមុខគូក្តី និង បើកផ្លូវឧទ្ធរណ៍តាមច្បាប់ ។

៧- បង្គាប់ឱ្យចុងចម្លើយបង់ប្រាក់ប្រដាប់ក្តីចំនួន ៧.០០០រៀល ក្នុងនោះមានប្រាក់ប្រដាប់ក្តី និង ប្រាក់ពន្ធបណ្តឹងចំនួន១.៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រៀល រង្វាន់ប្រគល់ដីកាកោះចំនួន៥.០០០រៀល សរុបចំនួន៧.០០០រៀល ដែលដើមចោទបានបង់រួចហើយ ហើយបង្គាប់ឱ្យចុងចម្លើយសងទៅដើមចោទវិញ និង បង់ពន្ធសមាមាត្រចំនួនមួយភាគរយលើថ្លៃដី ។

បានឃើញសេចក្តីសុំប្តឹងតវ៉ាលេខ ០៣ ចុះថ្ងៃទី១០-០១-៩៦ របស់ឈ្មោះ ពៅ ប៊ុង ប្តឹងមិនសុខចិត្តនឹងសេចក្តីវិនិច្ឆ័យរបស់តុលាការខេត្តកំពង់ស្ពឺទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៣១៧ ចុះថ្ងៃទី ២២-៦-៩៨ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ ៖

១- ទទួលពាក្យសុំដកពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០២-៨-១៩៩៧ របស់ឈ្មោះ ពៅ ប៊ុង

ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- ចំណាយរឿងក្តីលេខ២១៤ ចុះថ្ងៃទី ០៧-៥-៩៧ របស់សាលាឧទ្ធរណ៍ចេញពីបញ្ជីក្តី ។

៣- សំរេចកាត់យកប្រាក់ប្រដាប់ក្តីនៅជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០រៀល ដែលដើមបណ្តឹងឧទ្ធរណ៍បានបង់រួចហើយគឺពន្ធចុះបញ្ជីក្តី ១២៧៥រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២២៥រៀលចំណាយលើកិច្ចប្រគល់ដីកាកោះ ៥.០០០រៀល និងលើអាជ្ញាធរតុលាការ ៥.០០០រៀល ។

៤- សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ ។ បើកផ្លូវ ប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ២៧២ ចុះថ្ងៃទី០៩-៧-៩៨ របស់មេធាវី ចាំង សុធា ការពារប្រជាជន ១៨គ្រួសារ ប្តឹងមិនសុខចិត្តនឹងសេចក្តីសំរេច របស់សាលាឧទ្ធរណ៍ខាងលើ ។

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការថា : លើកបណ្តឹងសាទុក្ខចោល អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាពិចារណាតាមច្បាប់តទៅ ។

បានស្តាប់ពាក្យសុំឈប់ប្តឹងរបស់ឈ្មោះ ពៅ ប៊ុង ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ពាក្យសុំឈប់ប្តឹងរបស់អ្នកស្រីពៅ ប៊ុង និងចម្លើយបញ្ជាក់របស់អ្នកស្រី ហោ លន
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ២៧២ ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ១៩៩៨ របស់លោក ចាំង សុធា មេធាវីការពារប្រជាជន១៨គ្រួសារ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបាន ។

- យល់ឃើញថា តាមពាក្យបណ្តឹងពុំមានចុះថ្ងៃ ខែមេសា ឆ្នាំ១៩៩៨ ឈ្មោះពៅ ប៊ុង បានសុំដកបណ្តឹងឧទ្ធរណ៍របស់ខ្លួន នៅសាលាឧទ្ធរណ៍រួចហើយ ហើយការដែលលោកមេធាវី ប្តឹងសាទុក្ខមកតុលាការកំពូលនេះ មិនស្របតាមឆន្ទៈរបស់កូនក្តីលោកឡើយ ។

- យល់ឃើញថា អ្នកស្រីពៅ ប៊ុង បានដាក់ពាក្យសុំដកបណ្តឹងឧទ្ធរណ៍របស់ខ្លួនរួចហើយ ហើយអ្នកស្រីពុំបានមកចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះ កំបាំងមុខអ្នកស្រី ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីកាវិនិច្ឆ័យលេខ៣១៧ ចុះថ្ងៃទី ២២-៦-៩៨ របស់សាលា

ឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និង តាមច្បាប់ហើយ ។

## ហេតុដូច្នេះ

### វិនិច្ឆ័យសេចក្តីចំពោះមុខអ្នកស្រីហោ ឈន កំបាំងមុខអ្នកស្រី ពៅ ប៊ូង
### ប៉ុន្តែចាត់ទុកជាចំពោះមុខ

១_ បដិសេធបណ្តឹងសាទុក្ខលេខ ២៧២ ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ១៩៩៨ របស់លោកមេធាវី ជាំង សុធា ចោលជាអសារបង់ ។

២_ បញ្ជូនសំណុំរឿងរដ្ឋប្បវេណីលេខ២៣៣ ចុះថ្ងៃទី២៥_៨_៩៨ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍វិញ ដើម្បីចាត់ការតាមច្បាប់ ។

៣_ រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០រៀល ដែលអ្នកស្រី ពៅ ប៊ូង បានបង់រួចហើយគឺ ៖

_ ពន្ធចុះបញ្ជីក្តីនិងពន្ធហ្លឹងចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ,

_ ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០រៀល សរុប ១៩.០០០រៀល ។

៤_ សាលដីកានេះ ប្រកាសតាមសវនាការជាសាធារណៈ នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៨ ។